**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក**

# និយាមនៃបែបបទសំរាប់អនុវត្តសកម្មភាព (Standard Operating Procedures) ផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន នៅមណ្ឌលសុខភាព និង មន្ទីរពេទ្យបង្អែក

ដើម្បីធានាបាននូវប្រសិទ្ធិភាពនៃការអនុវត្តន៏គោលការណ៏ណែនាំជាតិស្តីពីការបង្ការការចម្លងមេរោគអេដស៏ពីម្តាយទៅកូនដែលបានកែសំរួលរួចនិងដែលបានអនុម័តយល់ព្រមដោយក្រសួងសុខាភិបាល ចុះថ្ងៃទី ២០កញ្ញា ឆ្នាំ២០០៥ និងដើម្បីធ្វើឱ្យសេវាបង្ការការចម្លងមេរោគអេដស៏ពីម្តាយទៅកូនមានលក្ខណៈជាស្តង់ដា (standard) មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារកនៃក្រសួង សុខាភិបាល ដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៏ សើស្បែក និងកាមរោគ បានរៀបចំនូវនិយាមនៃបែបបទសំរាប់អនុវត្តសកម្មភាពផ្តល់សេវាបង្ការការចម្លងមេរោគអេដស៏ពីម្តាយទៅកូននេះឡើង ដើម្បីឱ្យមណ្ឌលសុខភាព អតីតមន្ទីរពេទ្យស្រុក មន្ទីរពេទ្យបង្អែក និង មន្ទីរពេទ្យជាតិទាំងឡាយដែលមានផ្តល់សេវានេះ អនុវត្តតាមនីតិវិធីដូចខាងក្រោម:

## ១. សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅមណ្ឌលសុខភាព:

### ១.១.ការផ្តល់ប្រឹក្សាមុនធ្វើតេស្តឈាម និង ការធ្វើតេស្តឈាមរកមេរោគអេដស៍

- ត្រូវផ្តល់ព័ត៌មានស្តីពីបញ្ហាសុខភាពនានា ដោយរួមបញ្ចូលទាំងបញ្ហាមេរោគអេដស៏-ជម្ងឺអេដស៏ និង ការបង្ការការចម្លងមេរោគអេដស៏ពីម្តាយទៅកូន និងផ្តល់ប្រឹក្សាជាក្រុមមុនពេលធ្វើតេស្តឈាម ដើម្បីបង្ការការចម្លងមេរោគអេដស៏ពីម្តាយទៅកូនដល់ស្ត្រីមានផ្ទៃពោះទាំងអស់ព្រមទាំងស្វាមីរបស់នាងនៅបន្ទប់អប់រំម្តាយ។ បើសិនជាស្ត្រី ឬស្វាមីនោះចង់ទទួលការផ្តល់ប្រឹក្សាជាលក្ខណៈបុគ្គល ឬទាំងប្តីប្រពន្ធក្តី អ្នកផ្តល់ ប្រឹក្សាត្រូវតែផ្តល់ជូនតាមការស្នើសុំរបស់សាមីខ្លួន។
- ក្នុងករណីដែលអតិថិជនមានចំនួនតិចពេក មិនអាចធ្វើការផ្តល់ប្រឹក្សាជាក្រុមបាននៅថ្នាក់អប់រំម្តាយ អ្នកផ្តល់ប្រឹក្សាគប្បីផ្តល់ប្រឹក្សាជាលក្ខណៈឯកជន ឬជាលក្ខណៈប្តីប្រពន្ធ ដែលគួរផ្តល់ជូនដល់គ្រប់ស្ត្រីមានផ្ទៃពោះ ទាំងអស់ និងស្វាមីរបស់នាង។
- នៅពេលដែលអតិថិជនយល់ព្រមធ្វើតេស្តឈាម អ្នកផ្តល់ប្រឹក្សាត្រូវបូមឈាមអតិថិជន ដើម្បីបញ្ជូនទៅមន្ទីរពិសោធន៏នៃសេវាផ្តល់ប្រឹក្សាធ្វើតេស្តឈាមដោយស្ម័គ្រចិត្តដែលស្ថិតនៅជិតបំផុត ដោយមានបិទភ្ជាប់លេខកូដសម្ងាត់របស់សេវាបង្ការការចម្លងមេរោគអេដស៏ពីម្តាយទៅកូននៅលើបំពង់ទីបឈាម និងនៅលើលិខិត បញ្ជូនដែលបានផ្តល់ជូនជាស្តង់ដាប្រើប្រាស់សំរាប់ការស្នើសុំធ្វើតេស្តឈាមរកមេរោគអេដស៏។

- បុគ្គលិកនៅផ្នែកពិនិត្យផ្ទៃពោះត្រូវទទួលខុសត្រូវក្នុងការបញ្ជូនបំពង់ទីបឈាមទៅកាន់មន្ទីរពិសោធន៍ និង ទទួលយកលទ្ធផលតេស្តពីមន្ទីរពិសោធន៍មកវិញ។ ត្រូវឱ្យប័ណ្ណណាត់ជួបជាស្តង់ដាដល់អតិថិជន ដែលបានធ្វើតេស្តឈាម ដើម្បីឱ្យគាត់មកទទួលលទ្ធផលតេស្តឈាមវិញ។
- ប្រសិនបើមណ្ឌលសុខភាពនោះស្ថិតនៅក្នុងមន្ទីរពេទ្យបង្អែក អ្នកផ្តល់ប្រឹក្សានៃសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅផ្នែកសម្ភពនៃមន្ទីរពេទ្យនោះ គួរមកជួយផ្តល់ប្រឹក្សានៅមណ្ឌលសុខភាព ដើម្បីធានាថា សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅទីនោះដំណើរការបានយ៉ាងរលូនល្អ។
- ការពិនិត្យតាមដានសុខភាពម្តាយ និងទារកក្នុងផ្ទៃមុនពេលសំរាល ត្រូវដំណើរការជាធម្មតា។

## ១.២ ការផ្តល់ប្រឹក្សាក្រោយធ្វើតេស្តឈាមរកមេរោគអេដស៍

- ការផ្តល់ប្រឹក្សាក្រោយធ្វើតេស្តឈាមជាបុគ្គលឬជាលក្ខណៈប្តីប្រពន្ធ ត្រូវធ្វើនៅក្នុងបន្ទប់ដាច់ដោយឡែក ដោយអ្នកផ្តល់ប្រឹក្សាដែលមានជំនាញបណ្តុះបណ្តាលដោយក្រសួងសុខាភិបាល។
- លទ្ធផលតេស្តឈាមត្រូវផ្តល់ជូនអតិថិជន នៅក្នុងថ្ងៃតែមួយដែលអតិថិជនមកធ្វើតេស្តឈាម។ បើសិនជាអាចធ្វើបានគឺ គប្បីផ្តល់លទ្ធផលតេស្តឈាមភ្លាមៗក្នុងព្រឹកតែមួយ។ ការណាត់ជួបសំរាប់ទទួលលទ្ធផលតេស្តរបស់អតិថិជនម្នាក់ៗត្រូវបញ្ជាក់ពីពេលវេលា និងកាលបរិច្ឆេទឱ្យបានច្បាស់លាស់ ដើម្បីកាត់បន្ថយការរង់ចាំយូររបស់អតិថិជន។
- <u>សំរាប់ស្រ្តីមានផ្ទៃពោះ និង/ឬ ស្វាមី ដែលមានលទ្ធផលតេស្តអវិជ្ជមាន:</u> អ្នកផ្តល់ប្រឹក្សាត្រូវរំលឹកព័ត៌មានស្តីពីឥរិយាបថប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ និងរំលឹកពីវិធីនានាដើម្បីការពារខ្លួនឱ្យនៅតែអវិជ្ជមានមេរោគអេដស៍ជានិច្ច។ ព័ត៌មាននានាស្តីពីការចិញ្ចឹមកូនដោយទឹកដោះម្តាយ គួរតែរំលឹកឡើងវិញផងដែរនៅពេលផ្តល់ប្រឹក្សាក្រោយធ្វើតេស្តឈាមរកមេរោគអេដស៍។
- <u>សំរាប់ស្រ្តីមានផ្ទៃពោះ និង/ឬ ស្វាមី ដែលមានលទ្ធផលតេស្តវិជ្ជមាន:</u> អ្នកផ្តល់ប្រឹក្សាត្រូវផ្តល់ព័ត៌មានដល់គ្រប់ស្រ្តីមានផ្ទៃពោះដែលមានផ្ទុកមេរោគអេដស៍ និង/ឬ ស្វាមីដែលមានផ្ទុកមេរោគអេដស៍ពីសេវាថែទាំ គាំទ្រ និង ព្យាបាលបន្តដែលអាចទទួលយកបាន និង ពីផលប្រយោជន៍ និងគុណវិបត្តិនៃការប្រាប់ ឱ្យអ្នកដទៃដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន។ ការអប់រំអំពីការប្រើប្រាស់ស្រោមអនាម័យនៅតែមានសារៈសំខាន់ជានិច្ច បើទោះបីជាស្រ្តីមានផ្ទៃពោះ និង/ឬ ស្វាមីនោះមានផ្ទុកមេរោគអេដស៍ហើយក៏ដោយ។ ត្រូវពិភាក្សាដោយយកចិត្តទុកដាក់អំពីអន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និង រំលឹកឡើងវិញពីជំរើសនៃការចិញ្ចឹមកូនដល់ស្រ្តី។
- នៅពេលដែលស្រ្តីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ យល់ព្រមទទួលយកសេវាថែទាំនិងព្យាបាលបន្ត អ្នកផ្តល់ប្រឹក្សាត្រូវបញ្ជូនគាត់ទៅទទួលសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដែលស្ថិតនៅជិតបំផុត ដោយមានលិខិតបញ្ជូនជាស្តង់ដាប្រើប្រាស់សំរាប់ការបញ្ជូនអ្នកជម្ងឺផ្ទុកមេរោគអេដស៍ ដោយមានចុះលេខកូដសម្ងាត់របស់កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនផងដែរ។ ការបញ្ជូននេះ គឺដើម្បីឱ្យក្រុមគ្រូពេទ្យជំនាញផ្នែកថែទាំព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលឱសថប្រឆាំងមេរោគអេដស៍ (OI & ART team) ធ្វើការវាយតម្លៃលើ

សភាពជម្ងឺ ថាតើអ្នកជម្ងឺនេះត្រូវទទួលការព្យាបាលសកម្ម ឬទទួលការព្យាបាលបង្ការដោយឱសថប្រឆាំងមេរោគអេដស៍ និងដើម្បីឱ្យគាត់បានចុះឈ្មោះប្រើប្រាស់សេវាថែទាំ គាំទ្រ ផ្សេងៗដែលមាននៅក្នុងគំរោងថែទាំបន្ត។ លិខិតបញ្ជូនអ្នកជម្ងឺដែលបានបង្កើតឡើងរួមគ្នាដោយមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែកនិងកាមរោគ និងមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង ត្រូវបានប្រើប្រាស់សំរាប់ការបញ្ជូននេះ។

- នៅពេលដែលស្ត្រីមកទទួលសេវាថែទាំផ្ទៃពោះ អ្នកផ្តល់ប្រឹក្សាត្រូវផ្តល់ព័ត៌មានបន្ថែមដល់ស្ត្រីផ្ទុកមេរោគអេដស៍ដែលមិនព្រមទទួលយកការថែទាំ ព្យាបាលបន្ត ឬ មិនព្រមទទួលឱសថបង្ការប្រឆាំងមេរោគអេដស៍។ បើទោះបីជា អតិថិជនបដិសេធក្នុងការទទួលសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនក៏ដោយ បុគ្គលិកសុខាភិបាលត្រូវតែផ្តល់សេវាពិនិត្យផ្ទៃពោះជាធម្មតាដល់ស្ត្រីមានផ្ទៃពោះនោះដោយគ្មានការរើសអើងឡើយ។ ត្រូវលើកទឹកចិត្តឱ្យស្ត្រីផ្ទុកមេរោគអេដស៍ប្រើប្រាស់ស្រោមអនាម័យ ដើម្បីការពារការឆ្លងសារ ចុះសារឡើងនៃមេរោគអេដស៍។
- ត្រូវផ្តល់ឱសថជាតិដែក និង ចាក់ថ្នាំបង្ការជម្ងឺតេតាណូស និងថ្នាំបង្ការផ្សេងៗទៀតដល់ស្ត្រីផ្ទុកមេរោគអេដស៍ឱ្យដូចគ្នាទៅនឹងស្ត្រីដទៃទៀតដែរ ។
- ស្ត្រីមានផ្ទៃពោះទាំងអស់ ទោះជាអ្នកផ្ទុកមេរោគអេដស៍ក្តី អ្នកគ្មានផ្ទុកមេរោគអេដស៍ក្តី ត្រូវតែបានផ្តល់ការណាត់ជួបពិនិត្យផ្ទៃពោះឱ្យបានទៀងទាត់។ កាលបរិច្ឆេទណាត់ជួបក្នុងការមកពិនិត្យផ្ទៃពោះ និង ការព្យាបាលជម្ងឺឱកាសនិយមនិងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ គប្បីធ្វើឡើងនៅក្នុងថ្ងៃតែមួយ ដើម្បីសំរួលក្នុងការធ្វើដំណើររបស់ស្ត្រីមានផ្ទៃពោះ បើសិនជាអាចធ្វើទៅបាន។

## ២.សេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅមន្ទីរពេទ្យបង្អែក

- ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលត្រូវបានបញ្ជូនពីមណ្ឌលសុខភាពទៅសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ត្រូវទទួលបាននូវអាទិភាពមុនគេក្នុងការទទួលសេវាថែទាំបន្ត ដើម្បីកាត់បន្ថយរយៈពេលរង់ចាំរបស់ស្ត្រី និងដើម្បីកាត់បន្ថយការប្រឈមមុខនឹងការឆ្លងរោគផ្សេងៗ នៅក្នុងមន្ទីរពេទ្យ។
- គ្រូពេទ្យផ្នែកព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ត្រូវចុះឈ្មោះស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ទៅក្នុងសៀវភៅបញ្ជី ដោយអនុលោមទៅតាមនីតិវិធីអនុវត្តជាស្តង់ដានៃ សេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។
- ប្រសិនបើស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍គ្រប់ល័ក្ខខ័ណ្ឌទទួលបាននូវការព្យាបាលសកម្មដោយឱសថប្រឆាំងមេរោគអេដស៍ហើយ ស្ត្រីនោះគួរតែទទួលបាននូវការព្យាបាលឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។
- ប្រសិនបើស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ មិនទាន់គ្រប់ល័ក្ខខ័ណ្ឌទទួលការព្យាបាលសកម្មដោយឱសថប្រឆាំងមេរោគអេដស៍ទេ គ្រូពេទ្យផ្នែកព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ត្រូវផ្តល់ឱសថប្រឆាំងមេរោគអេដស៍ AZT (ARV PROPHYLAXIS: AZT) ដើម្បីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនចាប់ពីពេលដែលគភ៌អាយុបាន

២៨អាទិត្យឡើងទៅ រហូតដល់ពេល សំរាល។ ប្រសិនបើការវាយតម្លៃដើម្បីព្យាបាលសកម្មដោយឱសថប្រឆាំងមេរោគអេដស៍មិនទាន់អាចធ្វើទៅបាននៅដំណាក់កាលដំបូងនៃផ្ទៃពោះ គ្រូពេទ្យត្រូវធ្វើការវាយតម្លៃពីការព្យាបាលសកម្មដោយឱសថប្រឆាំងមេរោគអេដស៍ម្តងទៀត នៅមុនពេលដែលគភ៌មានអាយុ ២៨ អាទិត្យ។

- មុននឹងផ្តល់ឱសថ AZT ឬមុននឹងផ្តល់ AZT បន្ថែមដើម្បីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន គ្រូពេទ្យត្រូវត្រួតពិនិត្យមើលកំរិតគ្រាប់ឈាមក្រហម (Hemoglobine) របស់ស្ត្រីមានផ្ទៃពោះជាមុនសិន ដើម្បីវាយតម្លៃពីភាពស្លេកស្លាំង (Anemia) *(សូមអានសៀវភៅគោលការណ៍ណែនាំជាតិស្តីពីការអនុវត្តន៏ សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន)*។
- ដើម្បីធានាថា ស្ត្រីនោះបានទទួលសេវាថែទាំព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលបង្ការដោយឱសថប្រឆាំងមេរោគអេដស៍បានជាប់លាប់ខ្ជាប់ខ្ជួនល្អ និងបានត្រឡប់មកទទួលសេវាពិនិត្យផ្ទៃពោះតាមការណាត់ជួបបានត្រឹមត្រូវ ព្រមទាំងបានមកសំរាលកូននៅឯមន្ទីរពេទ្យដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនតាមការណែនាំរបស់គ្រូពេទ្យនោះ គ្រូពេទ្យនៅសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (OI/ART) ត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយក្រុមថែទាំអ្នកជម្ងឺអេដស៍តាមផ្ទះ ឬក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៍ ដោយមានការអនុញ្ញាតពីសាមីខ្លួន។
- ក្រុមព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងគ្រូពេទ្យនៅសេវាសម្ភពត្រូវរាយការណ៏ប្រាប់គ្នាទៅវិញទៅមកពីរាល់ករណីស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលមកទទួលសេវានៅផ្នែករបស់ខ្លួននៅរាល់ពេលប្រជុំប្រចាំខែរបស់ក្រុមការងារបច្ចេកទេស ដើម្បីងាយស្រួលក្នុងការតាមដានថែទាំបន្តដល់ស្ត្រីនោះ។

## ៣. សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅផ្នែកសម្ភព

### ៣.១. នៅពេលឈឺពោះសំរាល និង ពេលសំរាល

- រាល់ស្ត្រីដែលមកសំរាលកូននិងស្ត្រីដែលមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ត្រូវទទួលបាននូវព័ត៌មានស្តីពីការផ្តល់ប្រឹក្សាធ្វើតេស្តឈាមដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ និងព័ត៌មានស្តីពីអន្តរាគមន៏កាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។ ធ្វើដូចនេះ ស្ត្រីដែលមិនទាន់ដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន អាចនឹងទទួលបាននូវការប្រឹក្សានិងធ្វើតេស្តឈាមបានទាន់ពេល និងទទួលបាននូវអន្តរាគមន៏នានា ដើម្បីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនបានសមស្រប។
- ក្នុងករណីដែលស្ត្រីមានផ្ទៃពោះនោះមានផ្ទុកមេរោគអេដស៍ ហើយបានមកទទួលសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ឬ សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនរួចហើយ នោះអ្នកផ្តល់ប្រឹក្សា ឬ ឆ្មបត្រូវពិនិត្យមើលសៀវភៅតាមដានការថែទាំព្យាបាលរបស់អ្នកផ្ទុកមេរោគអេដស៍/អ្នកជម្ងឺអេដស៍ និង/ឬបណ្ណ័បញ្ជូនជម្ងឺ និង រាល់ឯកសារទាំងឡាយដែលស្ត្រីមានផ្ទៃពោះបានកាន់យកមកជាមួយ ដើម្បីងាយស្រួលក្នុងការផ្តល់ឱសថប្រឆាំងមេរោគអេដស៍ដល់ទារក។

- អ្នកផ្តល់ប្រឹក្សា ឬ ឆ្មប ត្រូវកត់ត្រារាល់ព័ត៌មានសំខាន់ៗទៅក្នុងសៀវភៅបញ្ជីកត់ត្រារបស់កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅផ្នែកសម្ភពដោយរួមបញ្ចូលទាំងព័ត៌មានដែលទាក់ទងនឹងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ឬការផ្តល់ឱសថប្រឆាំងមេរោគអេដស៍ដើម្បីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលគ្រូពេទ្យបានផ្តល់ឱ្យគាត់ទាំងនៅមុនពេលសំរាល ពេលសំរាល និង ក្រោយពេល សំរាល។
- ក្នុងករណីដែលស្ត្រីមានផ្ទៃពោះប្រាប់ថាគាត់មានផ្ទុកមេរោគអេដស៍ ហើយពុំដែលបានទៅទទួលសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ឬ សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅទីកន្លែងណាមួយទេ នោះអ្នកផ្តល់ប្រឹក្សា ឬឆ្មបត្រូវពិនិត្យមើលបណ្ណ័ធ្វើតេស្តឈាម និង រាល់ឯកសារទាំងឡាយដែលស្ត្រីមានផ្ទៃពោះបានកាន់យកមកជាមួយ ដើម្បីបញ្ជាក់ថាគាត់មានផ្ទុកមេរោគអេដស៍ពិតប្រាកដមែន។
- អ្នកផ្តល់ប្រឹក្សាត្រូវផ្តល់ឱសថប្រឆាំងមេរោគអេដស៍ដល់ម្តាយផ្ទុកមេរោគអេដស៍និងកូនរបស់គាត់ដោយយោងទៅតាមរបបឱសថដែលមានចែងក្នុងគោលការណ៍ណែនាំជាតិស្តីការបង្ការការចម្លងមេរោគអេដស៍ពី ម្តាយទៅកូន។
- ឱសថប្រឆាំងមេរោគអេដស៍សំរាប់ផ្តល់ដល់ស្ត្រីផ្ទុកមេរោគអេដស៍នៅពេលឈឺពោះសំរាល ត្រូវចេញវេជ្ជបញ្ជាដោយគ្រូពេទ្យផ្នែកសម្ភព ឬដោយគ្រូពេទ្យដែលទទួលខុសត្រូវយាមប្រចាំការ និងត្រូវផ្តល់ឱ្យស្ត្រីនិងកូនដោយអ្នកផ្តល់ប្រឹក្សាដែលបានទទួលការបណ្តុះបណ្តាល។ ប្រសិនបើគ្រូពេទ្យអវត្តមានប្រធានក្រុមអ្នកផ្តល់ប្រឹក្សា ឬ នាយសាលសម្ភព ឬ ប្រធានក្រុមយាម ដែលបានបណ្តុះបណ្តាលអំពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ត្រូវទទួលខុសត្រូវក្នុងការផ្តល់ឱសថប្រឆាំងមេរោគអេដស៍ជូនដល់ស្ត្រីដែលមានផ្ទុកមេរោគអេដស៍ និង កូនរបស់គាត់។
- នាយសាលផ្នែកសម្ភពមានភារកិច្ចជាអ្នកស្នើសុំឱសថប្រឆាំងមេរោគអេដស៍ ដើម្បីត្រៀមទុកផ្តល់ជូនស្ត្រីផ្ទុកមេរោគអេដស៍ និង កូនរបស់គាត់។ ឱសថដែលបានមកត្រូវរក្សាទុកក្នុងទូរចាក់សោរនៅផ្នែកសម្ភព ដូចឱសថផ្សេងៗទៀតដែរ។ សោរនេះត្រូវប្រគល់ឱ្យប្រធានក្រុមយាមនីមួយៗគ្រប់គ្រង ដើម្បីប្រើប្រាស់។ នាយសាលផ្នែកសម្ភពត្រូវត្រួតពិនិត្យមើលកាលបរិច្ឆេទរបស់ឱសថទាំងអស់ដែលមានស្តុកទុកនៅផ្នែកសម្ភព និង ត្រូវធានាឱ្យបាននូវការផ្គត់ផ្គង់ជាប្រចាំនូវឱសថដែលមិនហួសកាលបរិច្ឆេទប្រើប្រាស់។

**កត់សំគាល់**: *(សូមអានគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលមានរៀបរាប់លំអិតអំពីរបបឱសថប្រឆាំងមេរោគអេដស៍ សំរាប់ផ្តល់ឱ្យម្តាយផ្ទុកមេរោគអេដស៍ និងទារកដែលប្រឈមមុខ)។*

## ៣.២. មុនពេលចេញពីមន្ទីរពេទ្យ

- ចំពោះស្ត្រីផ្ទុកមេរោគអេដស៍ដែលចេញទៅផ្ទះមុនពេលកំណត់ គ្រូពេទ្យត្រូវចេញវេជ្ជបញ្ជាផ្តល់ឱសថប្រឆាំងមេរោគអេដស៍ដល់ស្ត្រី (ចំពោះស្ត្រីដែលបានទទួលឱសថព្យាបាលបង្ការ NVP នៅពេលឈឺពោះ សំរាល) និង កូនរបស់គាត់ឱ្យបានគ្រប់ចំនួនថ្ងៃតាមរូបមន្តដែលមានចែងនៅក្នុងសៀវភៅគោលការណ៍ណែនាំជាតិ។

- អ្នកផ្តល់ប្រឹក្សាត្រូវក្រើនរំលឹកដល់ស្ត្រីឱ្យប្រើឱសថប្រឆាំងមេរោគអេដស៍ឱ្យបានត្រឹមត្រូវ និង ជាប់លាប់ខ្ជាប់ខ្ជួនល្អ ទាំងខ្លួនឯងក្តី ទាំងកូនក្តី ។
- គ្រូពេទ្យ ឬ អ្នកផ្តល់ប្រឹក្សាត្រូវក្រើនរំលឹកដល់ស្ត្រីដែលកំពុងព្យាបាលសកម្មដោយឱសថប្រឆាំងមេរោគអេដស៍ឱ្យបន្តការព្យាបាលតទៅទៀត និងប្រាប់ស្ត្រីផ្ទុកមេរោគអេដស៍ទាំងអស់ឱ្យត្រឡប់ទៅទទួលសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍វិញតាមកាលបរិច្ឆេទដែលបាន កំណត់ដើម្បីធ្វើការតាមដានព្យាបាលបន្ត ។
- អ្នកផ្តល់ប្រឹក្សានៅផ្នែកសម្ភពត្រូវទាក់ទងជាមួយក្រុមថែទាំតាមផ្ទះ ឬ ក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៍-អ្នកជម្ងឺអេដស៍ (ឬក៏ឆ្មបបុរាណ ប្រសិនបើគ្មានក្រុមថែទាំតាមផ្ទះទេ) ដោយមានការយល់ព្រមពីស្ត្រី ដើម្បី :

  ក).ជួយតាមដានថែទាំបន្តដល់ម្តាយដែលមានផ្ទុកមេរោគអេដស៍និងកូនរបស់គាត់ ។

  ខ).ធានាថា ម្តាយនិងកូនបានប្រើប្រាស់របបឱសថប្រឆាំងមេរោគអេដស៍បានជាប់លាប់ខ្ជាប់ខ្ជួនល្អក្រោយពេលសំរាល ។

  គ).ធានាថាម្តាយបានទទួលការថែទាំនិងការគាំទ្របានល្អប្រសើរ ។

  ឃ).ធានាថាកុមារដែលប្រឈមនឹងការឆ្លងមេរោគអេដស៍ពីម្តាយ ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ឬ គ្លីនិកកុមារណាមួយដែលនៅជិតបំផុត ដើម្បីបានទទួលការថែទាំព្យាបាលបង្ការជម្ងឺឱកាសនិយម ។

  ង).ធានាថា កុមារទទួលបានសេវាចាក់ថ្នាំបង្ការ នៅឯមណ្ឌលសុខភាព ។
- មុនពេលដែលម្តាយចេញពីមន្ទីរពេទ្យ អ្នកផ្តល់ប្រឹក្សាត្រូវរំលឹកឡើងវិញ ពីព័ត៌មានអំពីការធ្វើតេស្តឈាមរកមេរោគអេដស៍ និង អន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដល់ម្តាយទាំងឡាយ ដែលមិនបានដឹងអំពីស្ថានភាពផ្ទុកមេរោគអេដស៍ខ្លួន ។

### ៣.៣. ក្នុងករណីដែលស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍មិនអាចមកសំរាលកូននៅមន្ទីរពេទ្យ

- គ្រូពេទ្យនៅផ្នែកសម្ភពដែលបានទទួលការបណ្តុះបណ្តាលអំពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ត្រូវផ្តល់ឱសថប្រឆាំងមេរោគអេដស៍សំរាប់បង្ការដល់កុមារតាមរយៈអ្នកមើលថែទាំ (ឧទាហរណ៍ : ឪពុក ឬ ជីដូន ។ល ។) ។
- ទារកដែលកើតពីម្តាយផ្ទុកមេរោគអេដស៍ដែលមិនបានមកសំរាលកូននៅក្នុងមន្ទីរពេទ្យដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនត្រូវទទួលបាននូវសេវាចាក់ថ្នាំបង្ការដូចកុមារដទៃទៀតដែរ និងត្រូវបានបញ្ជូនឱ្យទៅទទួលសេវាថែទាំតាមដានបន្តដូចគ្នានឹងកុមារប្រឈមដទៃទៀត ដែលសំរាលកូននៅក្នុងមន្ទីរពេទ្យផងដែរ ។

## ៤.សេវាថែទាំជម្ងឺអេដស៍កុមារនៅមន្ទីរពេទ្យបង្អែក

- សូមអាននិយាមនៃបែបបទសំរាប់ការអនុវត្តន៍ថែទាំកុមារដែលមានផ្ទុកមេរោគអេដស៍ដែលបានរៀបរៀងឡើងដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគ ។

### ៥. ករណីពិសេស

**<u>៥.១ រាជធានីភ្នំពេញ</u>: ចំពោះមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ និង មន្ទីរពេទ្យជាតិដែលមានផ្តល់សេវាពិនិត្យផ្ទៃពោះ សេវាធ្វើតេស្តឈាមរកមេរោគអេដស៍ សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននិងសេវាសំរាលកូន <u>ប៉ុន្តែមិនមានសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍</u>**

- ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ត្រូវប្រព្រឹត្តទៅតាមនីតិវិធីដែលបានលើកឡើងនៅ ផ្នែក១.១ និង ផ្នែក ១.២។
- ស្វាមីរបស់ស្ត្រីមានផ្ទៃពោះដែលបានរកឃើញថាមានផ្ទុកមេរោគអេដស៍ គប្បីត្រូវបញ្ជូនគាត់ឱ្យទៅទទួលសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ នៅមន្ទីរពេទ្យឬគ្លីនិកដែលនៅជិតបំផុត ហើយមានផ្តល់សេវានេះ។
- ចំពោះស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ហើយយល់ព្រមទទួលសេវាថែទាំបន្តនោះ អ្នកផ្តល់ប្រឹក្សាត្រូវបូមឈាមស្ត្រីនោះដាក់ក្នុងបំពង់ទីបឈាម K3 ដើម្បីបញ្ជូនទៅរាប់ចំនួនកោសិកា CD4 នៅមន្ទីរពិសោធន៍នៃ វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ។ បំពង់ទីបឈាមដែលត្រូវបញ្ជូនទៅឱ្យមន្ទីរពិសោធន៍ត្រូវបិទ លេខកូដនៃសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនរួមជាមួយលិខិតបញ្ជូន។ អ្នកមន្ទីរពិសោធន៍នៃមន្ទីរពេទ្យជាអ្នកទទួលខុសត្រូវក្នុងការបញ្ជូនបំពង់ទីបឈាមទៅ និងទទួលយកលទ្ធផលតេស្តឈាមពីមន្ទីរ ពិសោធន៍នៃវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ មកប្រគល់ឱ្យប្រធានក្រុមនៃអ្នកផ្តល់ប្រឹក្សា។
  - ក្នុងករណីដែលស្ត្រីមានកោសិកា CD4 តិចជាង ២៥០ ក្នុង១មម៣ ត្រូវបញ្ជូនស្ត្រីទៅទទួលការព្យាបាលសកម្មដោយឱសថប្រឆាំងមេរោគអេដស៍នៅឯមន្ទីរពេទ្យដែលមានសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដោយប្រើប្រាស់លិខិតបញ្ជូន។
  - ក្នុងករណីដែលស្ត្រីផ្ទុកមេរោគអេដស៍មិនទាន់គ្រប់ល័ក្ខខ័ណ្ឌទទួលការព្យាបាលសកម្មដោយឱសថប្រឆាំងមេរោគអេដស៍នៅឡើយ (កោសិកា CD4 ច្រើនជាង ២៥០ ក្នុង១មម៣) គ្រូពេទ្យដែលធ្វើការនៅសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនត្រូវផ្តល់ឱសថប្រឆាំងមេរោគអេដស៍ AZT ដល់ស្ត្រីដើម្បីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនចាប់ពីអាទិត្យទី ២៨ នៃ គភ៌រហូតដល់ពេលសំរាល។
  - ប្រសិនបើ ការវាយតម្លៃពីការព្យាបាលសកម្មដោយឱសថប្រឆាំងមេរោគអេដស៍មិនទាន់គ្រប់ល័ក្ខខ័ណ្ឌនឹងត្រូវបានទទួលនៅរយៈពេលដំបូងនៃផ្ទៃពោះ គ្រូពេទ្យត្រូវធ្វើការវាយតម្លៃដល់ស្ត្រីម្តងទៀតនៅមុនពេលគភ៌មានអាយុ ២៨អាទិត្យ។ បើសិនជាស្ត្រីនៅតែមានកោសិកា CD4 ខ្ពស់ ឬ មិនទាន់គ្រប់ល័ក្ខខ័ណ្ឌទទួលការព្យាបាលសកម្មដោយឱសថប្រឆាំងមេរោគអេដស៍នៅឡើយទេនោះ គ្រូពេទ្យនៃសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនត្រូវផ្តល់ឱសថ AZT ដល់ស្ត្រីដើម្បីបង្ការការចម្លងមេរោគអេដស៍ទៅកូន។

- មុននឹងផ្តល់ AZT ឬ ផ្តល់ AZT បន្ថែមទៀត គ្រូពេទ្យត្រូវពិនិត្យមើលភាពស្លេកស្លាំងរបស់ស្ត្រីដោយត្រួតពិនិត្យមើលកំរិតគ្រាប់ឈាមក្រហម (Hemoglobine) របស់ស្ត្រីមានផ្ទៃពោះ ឬ ពិនិត្យមើលភ្នាសនៃត្របកភ្នែកក្រោមរបស់ស្ត្រី បើសិនចាំបាច់។ ត្រូវផ្តល់ឱសថជាតិដែកដល់ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដូចស្ត្រីឯទៀតដែរ។ *(សូមអានគោលការណ៍ណែនាំស្តីពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនអំពីកំរិតគ្រាប់ឈាមក្រហម (Hemoglobine) និងកំហាប់របស់ឈាម (Hematocrite)*
- អ្នកផ្តល់ប្រឹក្សានៅតាមមណ្ឌលនីមួយៗ ត្រូវមានទំនាក់ទំនងជាមួយក្រុមថែទាំអ្នកជម្ងឺអេដស៍តាមផ្ទះ ឬ ក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៍ ដើម្បីឱ្យក្រុមនេះជួយក្នុងការតាមដានថែទាំស្ត្រីផ្ទុកមេរោគអេដស៍ និងកូន របស់គាត់ ដូចដែលបានបញ្ជាក់នៅផ្នែកទី២ និង ៣.២ ខាងលើ។
- ប្រសិនបើស្ត្រីរស់នៅតាមបណ្តាខេត្ត គ្រូពេទ្យត្រូវពិនិត្យមើលនូវលទ្ធភាពបញ្ជូនគាត់ទៅរកសេវាព្យាបាលជម្ងឺឱកាសនិយម និង ព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដែលមាននៅក្នុងខេត្តរបស់គាត់វិញ។
- ការពិនិត្យផ្ទៃពោះត្រូវធ្វើជាធម្មតា ដូចស្ត្រីមានផ្ទៃពោះដទៃទៀតដែរ ។
- ទិន្នន័យតាមមណ្ឌលនីមួយៗត្រូវផ្ញើទៅលេខាធិការដ្ឋានរបស់កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយ ទៅកូន នៃមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារកជារៀងរាល់ខែ។

## ៥.២ មន្ទីរពេទ្យដែលមានផ្តល់សេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ប៉ុន្តែមិនទាន់មានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន :

- គ្រូពេទ្យ ឬ អ្នកផ្តល់ប្រឹក្សានៅផ្នែកព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ត្រូវណែនាំ និងបញ្ជូនស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ឱ្យទៅពិនិត្យផ្ទៃពោះឱ្យបានទៀងទាត់ និងទៅសំរាលកូននៅមន្ទីរពេទ្យដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដើម្បីធានាថា ម្តាយនិងកូនបានទទួលឱសថបង្ការប្រឆាំងមេរោគអេដស៍បានពេញលេញ ទាំងមុនពេលសំរាល និងក្រោយពេលសំរាលកូន។
- គ្រូពេទ្យព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ត្រូវពិនិត្យមើលលទ្ធភាព ដើម្បីបញ្ជូនស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលរស់នៅក្រៅរាជធានីភ្នំពេញឱ្យទៅទទួលសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ឬ សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅក្នុងខេត្តដែលគេរស់នៅវិញ ដើម្បីសំរួលដល់ការធ្វើដំណើររបស់ស្ត្រី បើសិនជាមានការយល់ព្រមពីសាមីខ្លួន។
- បើសិនជាអាច មន្ទីរពេទ្យដែលមានសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍រួចហើយ គួរពិនិត្យលទ្ធភាពក្នុងការបង្កើតសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅក្នុងមន្ទីរពេទ្យដោយសហការជាមួយមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក។

### ៥.៣ មន្ទីរពេទ្យជាតិ កាល់ម៉ែត

- មន្ទីរពេទ្យកាល់ម៉ែត គឺជាមន្ទីរពេទ្យជាតិដែលមានសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ សេវាថែទាំព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងសេវាថែទាំគាំទ្រផ្សេងៗទៀត នៅក្នុងមន្ទីរពេទ្យតែមួយ ។ ដូចនេះការអនុវត្តន៍សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនគឺមានលក្ខណៈដូចគ្នានឹងការផ្តល់សេវានេះនៅតាមមន្ទីរពេទ្យបង្អែកខេត្ត-ក្រុងដែលបានរៀបរាប់ពីខាងលើដែរ ។

### ៥.៤ មន្ទីរពេទ្យកុមារជាតិ

- កុមារដែលសំរាលពីម្តាយដែលមានផ្ទុកមេរោគអេដស៍ទាំងអស់នៅជុំវិញរាជធានីភ្នំពេញ ត្រូវបានបញ្ជូនឱ្យទៅទទួលសេវាថែទាំបន្តនៅឯមន្ទីរពេទ្យកុមារជាតិ នៅពេលដែលទារកមានអាយុ៦សប្តាហ៍ ។
- មន្ទីរពេទ្យកុមារជាតិត្រូវសហការជាមួយមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារកក្នុងការប្រមូលរបាយការណ៍កុមារដែលប្រឈមមុខ ដើម្បីធ្វើឱ្យសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនមានលក្ខណៈគ្រប់ជ្រុងជ្រោយ ។

## ៦-មណ្ឌលសុខភាព (អតីតមន្ទីរពេទ្យស្រុក)

ចំពោះមណ្ឌលសុខភាពដែលជាអតីតមន្ទីរពេទ្យស្រុក ហើយដែលមានគ្រូពេទ្យនិងបុគ្គលិកគ្រប់គ្រាន់ ដើម្បីផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ត្រូវបានអនុញ្ញាតឱ្យផ្តល់ឱសថ AZT បង្ការការចម្លងមេរោគអេដស៍ដល់ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ ប្រសិនបើស្ត្រីនោះមិនទាន់គ្រប់ល័ក្ខខ័ណ្ឌទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅឡើយទេ ឬ ក៏ស្ត្រីមិនអាចទៅទទួលសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បាន។ ការផ្តល់ AZT ដល់ស្ត្រីផ្ទុកមេរោគអេដស៍ ដោយគ្រូពេទ្យនៅឯអតីតមន្ទីរពេទ្យស្រុកត្រូវបានអនុញ្ញាត លុះណាតែមានការវាយតម្លៃពីថ្នាក់ខេត្ត និង ថ្នាក់ជាតិ ។

## ៧-ការរាយការណ៍ និង ការត្រួតពិនិត្យតាមដាន

- បញ្ជីកត់ត្រាជាស្តង់ដានៃសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនសំរាប់ប្រើប្រាស់នៅកន្លែងថែទាំផ្ទៃពោះនិង នៅផ្នែកសម្ភពត្រូវបានយកមកប្រើប្រាស់នៅគ្រប់មណ្ឌលសុខភាព, មន្ទីរពេទ្យបង្អែក, អតីតមន្ទីរពេទ្យស្រុក និងមន្ទីរពេទ្យជាតិដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។ បញ្ជីកត់ត្រាទាំងនេះត្រូវបានប្រើប្រាស់ដើម្បីជាជំនួយក្នុងការស្រង់ទិន្នន័យសំរាប់ធ្វើរបាយការណ៍សង្ខេបប្រចាំខែ ។
- ប្រធានក្រុមសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន នៅផ្នែកពិនិត្យផ្ទៃពោះ និង នាយសាលនៃផ្នែកសម្ភពមានតួនាទីជាអ្នកទទួលខុសត្រូវក្នុងការបំពេញទំរង់បែបបទ និងធ្វើរបាយការណ៍ប្រចាំខែទៅអ្នកសំរបសំរួលថ្នាក់ស្រុកប្រតិបត្តិ ។
- អ្នកសំរបសំរួលថ្នាក់ស្រុកប្រតិបត្តិ ជាអ្នកទទួលខុសត្រូវក្នុងការបញ្ជូនរបាយការណ៍សរុបនៅស្រុកប្រតិបត្តិទៅអ្នកសំរបសំរួលថ្នាក់ខេត្តជារៀងរាល់ខែ ។

- អ្នកសំរបសំរួលថ្នាក់ខេត្ត ជាអ្នកប្រមូលផ្តុំរបាយការណ៍ពីគ្រប់ស្រុកប្រតិបត្តិជារៀងរាល់ខែ រួមទាំងរបាយការណ៍របស់មណ្ឌលនីមួយៗមកជាមួយផង ដើម្បីបញ្ជូនទៅលេខាធិការដ្ឋាននៃមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារកជារៀងរាល់ខែដោយមិនឱ្យហួសពីចុងសប្តាហ៍ទីមួយនៃខែបន្ទាប់ ។
- ចំពោះសេវានៅមន្ទីរពេទ្យជាតិ ត្រូវរាយការណ៍ដោយផ្ទាល់មកលេខាធិការដ្ឋាននៃមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារកតែម្តង ។
- លេខាធិការដ្ឋាននៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៃមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារកត្រូវប្រមូលផ្តុំទិន្នន័យពីគ្រប់ខេត្តទាំងអស់ និងផ្ញើជូនទៅក្រសួងសុខាភិបាល (នាយកដ្ឋានផែនការ) ជារៀងរាល់ត្រីមាស ។

---

រាជធានីភ្នំពេញ, ថ្ងៃទី ៦ខែ មេសា ឆ្នាំ ២០០៦



ឯ.ឧ.សាស្ត្រាចារ្យ **អេង ហួត**

រដ្ឋលេខាធិការក្រសួងសុខាភិបាល